ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 / 12 942 019, Fax: (855) 23 883 750
E-mail: comfrel@online.com.kh or comfrel@forum.org.kh Site: http://www.comfrel.org

គណៈកម្មាធិការនាយក
BOARD OF DIRECTORS

លោក ធុន សារាយ
Mr. THUN SARAY
ជាតំណាងទី១ និង
ប្រធាន ADHOC

លោកស្រី អ៊ុង ចាន់ថុល
Ms. OUNG Chanthol
ជាតំណាងទី២ និង
នាយិកា CWCC

លោក យឹម ប៉ូ
Mr. YIM Po អគ្គហិរញ្ញិក
និងនាយក CCPCR

លោក សុក សំអឿន
Mr. SOK Sam Oeun
នាយក CDP

លោកស្រី ទីវ សារ៉ាយេត
Ms. TIV Sarayet
សហនាយិកា WMC

លោក យង់ គិមអេង
Mr. YONG Kim Eng
ប្រធាន KYA

លោក អ៊ុក វណ្ណដេត
Mr. OUK Vandeth
នាយក LAC

លោក ស៊ីល វិនេត្រ
Mr. SIL Vinet នាយក SEDOC

លោក ភួង សិទ្ធិ
Mr. PHUONG Sith

លោក សិន សែត
Mr. SEN Set

លោក មុំ សារិន
Mr. MOM Sarin
នាយក KKKHRA

លោក ទូច ទុម្ព
Mr. Touch Tum
នាយក VIGILANCE

ស.ប្រ.ក/លេខ ០៧/០៧ គ.យ.ស.ប/អ.ក

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលនៃការអង្កេតទៅលើប្រព័ន្ធផ្សព្វផ្សាយ
# ពីថ្ងៃទី ០១-១៥ ខែ មីនា ឆ្នាំ ២០០៧

*ភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧*

ខុមហ្វ្រែល បាននិងកំពុងធ្វើការអង្កេតប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចមួយចំនួនរួមមាន ទូរទស្សន៍ជាតិកម្ពុជា ទូរទស្សន៍ស៊ីធីអិន វិទ្យុជាតិកម្ពុជាក៏រិត FM96MHz វិទ្យុជាតិក៏រិត AM918KHz (ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកទាំង ៤នេះបាននិងកំពុងត្រូវបានអង្កេតការផ្សាយ ចាប់ពីម៉ោង១៧:០០ ដល់ម៉ោង២៣:០០ ជារៀងរាល់ថ្ងៃ) វិទ្យុបារាំងអន្តរជាតិ វិទ្យុអាស៊ីសេរី និងវិទ្យុសំលេង សហរដ្ឋអាមេរិក (វិទ្យុអន្តរជាតិទាំងបីនេះបាននិងកំពុងត្រូវបានអង្កេតការផ្សាយតាមកម្មវិធីរៀងរាល់យប់)។ ខុមហ្វ្រែលក៏សង្កេតប្រព័ន្ធផ្សព្វផ្សាយបោះពុម្ពផងដែរ មានសារព័ត៌មានរស្មីកម្ពុជា និងកោះសន្តិភាព។

## <u>លទ្ធផលអង្កេតប្រព័ន្ធផ្សព្វផ្សាយរដ្ឋ</u>

សរុបលទ្ធផលអង្កេតទៅលើតែប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋរួមគ្នា (ទូរទស្សន៍ជាតិកម្ពុជា វិទ្យុជាតិកម្ពុជាក៏រិត FM96MHz និងវិទ្យុជាតិក៏រិត AM918KHz) បង្ហាញថា ការផ្សាយពីគណបក្សនយោបាយនៅតែបន្ត**មានភាពលំអៀងយ៉ាងខ្លាំងទៅរកគណបក្ស (កាន់អំណាច) ប្រជាជនកម្ពុជា** ដែលត្រូវបានផ្សព្វផ្សាយរហូតដល់ ៨២% (ស្មើនឹង ៤៦នាទី ៣០វិនាទី)។ ប្រព័ន្ធផ្សព្វផ្សាយនេះ នៅតែបន្តការផ្សាយ**អតុល្យភាពយ៉ាងខ្លាំងដដែល**។ គណបក្សនយោបាយចំនួន ៣ទៀត គឺគណបក្ស ហ៊្វុនស៊ិនប៉ិច ត្រូវបានផ្សព្វផ្សាយចំនួន ៧% (ស្មើនឹង ៤នាទី ៣វិនាទី) គណបក្ស នរោត្តម រណឫទ្ធិ ទទួលបាន ៦% (ស្មើនឹង ៣នាទី ១៥វិនាទី) និងគណបក្ស សម រង្ស៊ី ទទួលបាន ៥% (ស្មើនឹង ២នាទី ៤៩វិនាទី)។

គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច ត្រូវបានគ្របដណ្តប់ដោយព័ត៌មាន**បែបអព្យាក្រឹត** ខណៈដែលភាពអវិជ្ជមានត្រូវបានឮតិចតួចប៉ុណ្ណោះដូចជា ការផ្សាយពីមន្ត្រីមកពីគណបក្សប្រជាជនកម្ពុជាទាក់ទងទៅនឹង**បញ្ហាយកដីរដ្ឋ និងរំលោភយកដី** របស់ប្រជាពលរដ្ឋជាដើម។ **ដោយឡែកគណបក្សនរោត្តម រណឫទ្ធិ**

**ត្រូវគ្របដណ្តប់ដោយព័ត៌មានបែបអវិជ្ជមាន**ច្រើនលើសលប់រហូតដល់ **៩២%** (ស្មើនឹង ២នាទី ៥៩វិនាទី) នៃរយៈពេលសរុបដែលគណបក្សនេះត្រូវបានផ្សព្វផ្សាយ។ ការផ្សព្វផ្សាយ**បែបអវិជ្ជមាននេះ**មានដូចជាការលើកឡើងពីភាពទន់ខ្សោយ និងការដែលមន្ត្រីរបស់គណបក្សនេះ**ជំពាក់លុយរដ្ឋជាដើម**។ ចំណែកគណបក្ស **សម រង្ស៊ី ត្រូវបានផ្សព្វផ្សាយបែបអវិជ្ជមាន** ៦៣% (ស្មើនឹង ១នាទី ៤៧វិនាទី) ដូចជាការផ្សាយថា គណបក្ស នេះ**ប្រព្រឹត្តអំពើពុករលួយក្នុងការរៀបចំលំដាប់បេក្ខជន**សំរាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់។ ភាពអវិជ្ជមានរបស់គណបក្ស នរោត្តម រណឫទ្ធិ និងគណបក្ស សម រង្ស៊ី **ត្រូវបានផ្សព្វផ្សាយដោយវិទ្យុជាតិកំរិត AM918KHz តែមួយគត់**ក្នុងចំណោមប្រព័ន្ធផ្សព្វផ្សាយរដ្ឋទាំងបី។ ចំណែកវិទ្យុជាតិកំរិត FM96MHz មិនបានធ្វើសេចក្តីរាយការណ៍ពីគណបក្សនយោបាយណាចេញឈ្មោះចំនោះទេក្នុងរយៈពេលអង្កេតនេះ។

## <u>លទ្ធផលអង្កេតទូរទស្សន៍ស៊ីធីអ៊ិន</u>

សំរាប់បណ្តាញទូរទស្សន៏កម្ពុជា (ស៊ីធីអិន) បានបង្ហាញគណបក្សនយោបាយចំនួនបីក្នុងរយៈពេល អង្កេតនេះដែលខុសពីខែមុនដែលមានតែគណបក្សនយោបាយតែមួយបុណ្ណោះគឺគណបក្សប្រជាជនកម្ពុជា។ គណបក្ស **នរោត្តម រណឫទ្ធិ ទទួលបានការផ្សព្វផ្សាយច្រើនលើសលប់រហូតដល់ ៧១%** (ស្មើនឹង ៣នាទី ៣៨វិនាទី)។ គណបក្សប្រជាជនកម្ពុជាទទួលបាន ២៣% ខណៈដែលគណបក្ស ហ៊្វុនស៊ិនប៉ិច ត្រូវបានផ្សព្វផ្សាយ ៦% (ស្មើនឹង ២០វិនាទី)។

នៅក្នុងការផ្សព្វផ្សាយរបស់ស៊ីធីអ៊ិនដដែល មានតែគណបក្ស**ប្រជាជនកម្ពុជាមួយប៉ុណ្ណោះដែលត្រូវបានផ្សព្វផ្សាយបែបវិជ្ជមាន** ៣៦% (ស្មើនឹង ២៥វិនាទីនៃការផ្សាយពីគណបក្សនេះសរុប)។ ភាពអវិជ្ជមានត្រូវបានឮសំរាប់តែគណបក្ស នរោត្តម រណឫទ្ធិ តែមួយប៉ុណ្ណោះ (៧២% ស្មើនឹង ២នាទី ៣៦វិនាទី) ដូចជាការធ្វើសេចក្តីរាយការណ៍ពីការកាត់ទោសព្រះប្រធានគណបក្សនេះជាដើម។ ចំណែកគណបក្ស ហ៊្វុនស៊ិនប៉ិចត្រូវបានរាយការណ៍បែបអព្យាក្រឹត ១០០% ទាក់ទងនឹងការកាត់ទោសសម្តេចក្រុមព្រះដែលត្រូវបានចោទពីបទលក់ទីស្នាក់ការគណបក្សហ៊្វុនស៊ិនប៉ិចខុសច្បាប់។

## <u>លទ្ធផលអង្កេតប្រព័ន្ធផ្សព្វផ្សាយ វិទ្យុអន្តរជាតិទាំងបី (RFI, RFA, VOA)</u>

បើបូកបញ្ចូលវិទ្យុអន្តរជាតិទាំងបីរួមគ្នាឃើញថា គណបក្សនយោបាយទាំង១២ត្រូវបានលើកឡើង និងផ្សព្វផ្សាយ។ ក្នុងនោះគណបក្សនយោបាយចំនួន៤ (គណបក្ស ប្រជាជនកម្ពុជា គណបក្ស ហ៊្វុនស៊ិនប៉ិច និងគណបក្ស នរោត្តម រណឫទ្ធិ) បានគ្របដណ្តប់ការផ្សាយនេះ។ គណបក្ស សម រង្ស៊ី បាននាំមុខដោយត្រូវបានផ្សព្វផ្សាយ ២៦% (ស្មើនឹង ២ម៉ោង ២៦នាទី ២៨វិនាទី) នៃរយៈពេលសរុបផ្សាយពីគណបក្សនយោបាយ។ ចំណែកគណបក្ស ប្រជាជនកម្ពុជាត្រូវបានផ្សព្វផ្សាយច្រើនលំដាប់ទីពីរគឺ ២៤% (ស្មើនឹង ២ម៉ោង ១៤នាទី ២៨វិនាទី)។ គណបក្ស ហ៊្វុនស៊ិនប៉ិច ទទួលបាន

២០% (ស្មើនឹង ១ម៉ោង ៤៩នាទី ២វិនាទី) ហើយគណបក្ស នរោត្តម រណឫទ្ធិ ត្រូវបានផ្សព្វផ្សាយ ១៥% (ស្មើនឹង ១ម៉ោង ២៦នាទី ២០វិនាទី)។ ចំណែកគណបក្សចំនួន ៨ទៀតរួមគ្នាត្រូវបានផ្សព្វផ្សាយ ១៥% (ស្មើនឹង ១ម៉ោង ២៥នាទី ២២វិនាទី)។ ការផ្សព្វផ្សាយភាគច្រើនគឺក្នុងន័យអព្យាក្រឹត។ ការផ្សព្វផ្សាយបែបវិជ្ជមាន និងអវិជ្ជមាន មានចំពោះគណបក្សមួយចំនួនផងដែរ។

ក្នុងរយៈពេលអង្កេតនេះ មានតែវិទ្យុអាស៊ីសេរីប៉ុណ្ណោះដែលបានរាយការណ៍ពីគណបក្សនយោបាយទាំង១២ ខណៈដែលប្រព័ន្ធផ្សព្វផ្សាយ២ទៀត ធ្វើសេចក្ដីរាយការណ៍ពីគណបក្សចំនួនតែ៦ប៉ុណ្ណោះ។ គួរកត់សំគាល់ថា វិទ្យុអាស៊ីសេរី បានខិតខំយកចិត្តទុកដាក់ផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការបោះឆ្នោត ដោយបានបន្ថែមពេលវេលាផ្សាយរបស់ខ្លួនរយៈពេល១ម៉ោង (សរុប ៣ម៉ោងក្នុង១ថ្ងៃ) ទៀតផងដែរ ហើយការផ្សាយនេះភាគច្រើនគឺទាក់ទងទៅនឹងការបោះឆ្នោត និងការប្រឡូកខ្លួនរបស់ស្ត្រីនៅក្នុងវិស័យនយោបាយ ដូចជាការចាក់ផ្សាយវេទិការរបស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យ NDI ស្ដីពីចលនាស្ត្រីក្នុងឆាកនយោបាយ ដែលក្នុងឱកាសនោះស្ត្រីជាអ្នកដឹកនាំមកពីគណបក្ស ប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្ស សម រង្ស៊ី បាននិយាយពីចំនុចខ្លាំង និងចំនុចខ្សោយរបស់ស្ត្រី។

## លទ្ធផលអង្កេតប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចទាំងអស់

សរុបលទ្ធផលនៃការអង្កេតប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិចទាំងអស់បានបង្ហាញឱ្យឃើញថា គណបក្សនយោបាយទាំង១២ ត្រូវបានឮឈ្មោះ និងផ្សព្វផ្សាយ។ គណបក្ស ប្រជាជនកម្ពុជា ត្រូវបានផ្សព្វផ្សាយច្រើនជាងគេរហូតដល់ ២៩% (ស្មើនឹង ៣ម៉ោង ៣នាទី)។ គណបក្ស សម រង្ស៊ី ត្រូវបានផ្សព្វផ្សាយច្រើនលំដាប់ទីពីរ ២៤% (ស្មើនឹង ២ម៉ោង ២៩នាទី ២៣វិនាទី) គណប្ប ហ៊្វុនស៊ិនប៉ិច ទទួលបាន ១៨% (ស្មើនឹង ១ម៉ោង ៥៣នាទី ១៩វិនាទី) និងគណបក្ស នរោត្តម រណឫទ្ធិ ត្រូវបានផ្សព្វផ្សាយចំនួន ១៥% (ស្មើនឹង ១ម៉ោង ៣៣នាទី ១១វិនាទី)។ ចំណែកគណបក្សចំនួន៨ផ្សេងទៀតរួមគ្នា ទទួលបានការផ្សព្វផ្សាយ ១៤% (ស្មើនឹង ១ម៉ោង ២៦នាទី ១៧វិនាទី)។

ខ្លឹមសារផ្សព្វផ្សាយភាគច្រើនគឺក្នុងន័យអព្យាក្រឹតសំរាប់គណបក្សនយោបាយទាំងអស់។ មានគណបក្សនយោបាយតែ៥ប៉ុណ្ណោះ ដែលត្រូវបានផ្សព្វផ្សាយបែបអវិជ្ជមាន។ ក្នុងនេះភាពអវិជ្ជមានរបស់គណបក្ស នរោត្តម រណឫទ្ធិ (ធៀបទៅនឹងរយៈពេលសរុបផ្សាយពីគណបក្សនេះ) ត្រូវបានផ្សព្វផ្សាយច្រើនជាងគេរហូត ដល់ ២០% (ស្មើនឹង ១៨នាទី ៤៣វិនាទី) ដូចជាការផ្សាយពីការផ្ដន្ទាទោស ទ្រង់រណឫទ្ធិឱ្យជាប់ពន្ធនាគារ១៨ខែ និងបង់ប្រាក់ ១៥ម៉ឺនដុល្លាអាមេរិក ពីបទរំលោភសេចក្ដីទុកចិត្តលក់ទីស្នាក់ការ គណបក្សហ៊្វុនស៊ិនប៉ិចជាដើម។ គណបក្ស ប្រជាជនកម្ពុជា ត្រូវបានផ្សព្វផ្សាយបែបអវិជ្ជមាន ៩% (ស្មើនឹង ១៥នាទី ៤វិនាទី) ដូចជាការលើកឡើងថា គណបក្សប្រជាជនកម្ពុជាបានធ្វើការឃោសនាមុនកាលកំណត់ និងធ្វើអំពើខុសច្បាប់ជាដើម។ គណបក្ស រណសិរ្សសង្គមជាតិនិយម ត្រូវបានផ្សព្វផ្សាយបែបអវិជ្ជមាន

នេះប្រមាណ ៤% (ស្មើនឹង៣៥វិនាទី) ធៀបនឹងរយៈពេលសរុបដែលគណបក្សនេះទទួលបាន។ ចំណែកភាពអវិជ្ជមានរបស់គណបក្ស សម រង្ស៊ី ត្រូវបានផ្សព្វផ្សាយ ៣% (ស្មើនឹង ៥នាទី ៦វិនាទី) ដូចជាការផ្សាយរបស់វិទ្យុ AM 918 KHz នៅថ្ងៃទី ០១ ខែមីនា ថា គនបក្សប្រឆាំង ក៏មានបញ្ហាប្រព្រឹត្តអំពើពុករលួយ...គ្រាន់តែការដាក់ឈ្មោះបេក្ខជនលេខ១ លេខ២ ក៏ពាក់ព័ន្ធនឹងអំពើពុករលួយដែរ...។ គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបានការផ្សព្វផ្សាយបែបអវិជ្ជមាននេះ ២% (ស្មើនឹង ២នាទី ៤៦វិនាទី)។ ភាពវិជ្ជមាន របស់គណបក្សនយោបាយទាំង១២ ត្រូវបានផ្សព្វផ្សាយផងដែរក្នុងរយៈពេលអង្កេតនេះ។

កម្មវិធី ស្ប៉ត(រឿងខ្លី) និងព័ត៌មានស្តីពីការបោះឆ្នោតត្រូវបានផ្សព្វផ្សាយរយៈពេល ៧ម៉ោង ២៨នាទី ៣៩វិនាទី។ ការផ្សព្វផ្សាយភាគច្រើនមានដូចជាកម្មវិធីស្វែងយល់ពីការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង ស្ប៉តផលិតដោយអង្គការមិនមែនរដ្ឋាភិបាលរួមទាំងខុមហ្វ្រែលផងដែរ។

បញ្ហាស្ត្រីក្នុងវិស័យនយោបាយ ដូចជាការផ្សាយពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលចំពោះស្ត្រីចូលរួមក្នុងវិស័យនយោបាយ ការផ្សាយពីវេទិការស្ត្រីក្នុងឆាកនយោបាយរបស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) ជាដើម ត្រូវបានលើកឡើងយ៉ាងច្រើនរហូតដល់ ៤ម៉ោង ៤១នាទី ២៥វិនាទី បើប្រៀបធៀបទៅនឹងការផ្សាយក្នុងខែកុម្ភៈមានរយៈពេលដ៏តិចតួចបំផុតត្រឹមតែ ៣នាទី ៣២វិនាទីប៉ុណ្ណោះ។

ក្នុងពេលវេលាអង្កេតនេះ ស្ត្រីជាបេក្ខជនសំរាប់ឈរឈ្មោះបោះឆ្នោត ឬមេឃុំ ចៅសង្កាត់ជាស្ត្រីត្រូវបានផ្សព្វផ្សាយ ឬលើកឡើងក្នុងរយៈពេល ៣ម៉ោង ៣០នាទី ១៧វិនាទី ដូចជាការចាក់ផ្សាយរបស់វិទ្យុអាស៊ីសេរីស្តីពីស្ត្រី និងការដឹកនាំដែលបេក្ខជនមកពីគណបក្ស សម រង្ស៊ី និងប្រជាជនកម្ពុជា អាចថ្លែងពីគោលនយោបាយរបស់គណបក្សរបស់ខ្លួនក្នុងការលើកតំកើងស្ត្រីនៅក្នុងវេទិការពិភាក្សារបស់ NDI។

ការលើកឡើងពីជនពិការក្នុងវិស័យនយោបាយមិនត្រូវបានផ្សព្វផ្សាយទេក្នុងរយៈពេលអង្កេតនេះ។

ក្នុងរយៈពេលអង្កេតនេះមានប្រព័ន្ធផ្សព្វផ្សាយចំនួនពីរបានផ្សព្វផ្សាយការអំពាវនាវឱ្យបោះឆ្នោតជូនគណបក្សនយោបាយជាចំហរ។ ក្នុងនោះ មានវិទ្យុអាស៊ីសេរី ដូចជាការចាក់ផ្សាយវេទិការរបស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យដែលមន្ត្រីរបស់គណបក្សប្រជាជនកម្ពុជាបាន**អំពាវនាវសុំឱ្យប្រជាពលរដ្ឋបោះឆ្នោតជូនគណបក្ស ប្រជាជនកម្ពុជា**។ ទូរទស្សន៍ស៊ីធីអិនបានចាក់ផ្សាយសម្តីរបស់ពិធីករ ជុំ កុសល **ក្នុងន័យឱ្យពលរដ្ឋបោះឆ្នោតជូនគណបក្ស ប្រជាជនកម្ពុជា ជាកិច្ចតប**

ស្នងគុណដល់សម្តេចហ៊ុន សែន ដែលបានអំណោយដ៏ថ្លៃថ្លាជាកាដូរ (ផ្ទះ) ដល់អ្នករស់នៅបុរីកីឡា និងពាក្យសម្តីថា បើចង់ឱ្យគំរោងនៅមានត ត្រូវតែគាំទ្រគណបក្សប្រជាជនកម្ពុជាតទៅទៀត។

**<u>លទ្ធផលនៃប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព (កោះសន្តិភាព និងរស្មីកម្ពុជា)</u>**

មានតែគណបក្សនយោបាយចំនួន៥ គឺគណបក្សប្រជាជនកម្ពុជា គណបក្ស ហ៊្វុនស៊ិនប៉ិច គណបក្សនរោត្តម រណប្ញទ្ធិ គណបក្ស សម រង្ស៊ី និងគណបក្ស រណសិរ្សសង្គមជាតិនិយមប៉ុណ្ណោះ ដែលត្រូវបានផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ បោះពុម្ព (កោះសន្តិភាព និងរស្មីកម្ពុជា) ទាំងពីររួមគ្នា។ គណបក្សប្រជាជនកម្ពុជា ត្រូវបានផ្សព្វផ្សាយច្រើន ជាងគេគឺ ៧៦% (ស្មើនឹង១៩អត្ថបទ) ច្រើនជាងចំនួនសរុបនៃការផ្សាយពីគណបក្សផ្សេងៗទៀតបូកបញ្ចូលគ្នា។ ប្រព័ន្ធផ្សព្វផ្សាយ បោះពុម្ពទាំងពីរនេះបានផ្សព្វផ្សាយភាគច្រើនពីភាពវិជ្ជមានរបស់គណបក្សប្រជាជនកម្ពុជា ដែលមានរហូតដល់ទៅ ៧៩% (ស្មើនឹង ១៥អត្ថបទ នៃការផ្សាយពីគណបក្សនេះសរុប) ហើយភាពអវិជ្ជមានរបស់គនបក្សនេះមានតែមួយអត្ថបទ ប៉ុណ្ណោះ។ ការផ្សាយភាគច្រើនគឺជាការបញ្ចូលសមាជិកថ្មី និងការលើកសរសេរពីការដឹកនាំរបស់គណបក្សនេះ។ ខណៈ ដែលគណបក្ស៤ផ្សេងទៀតរួមគ្នា ដែលទទួលបានការផ្សាយសរុបតែ២៤% (ស្មើនឹង ៦អត្ថបទ) ត្រូវគ្របដណ្តប់ដោយ ព័តិមានបែបអវិជ្ជមានចំនួន៤អត្ថបទ (ស្មើនឹង៦៧%នៃការផ្សាយពីគណបក្សទាំង៤នេះរួមគ្នា) ដូចជាការផ្សាយពីការកាត់ ទោសសម្តេចក្រុមព្រះ ព្រះប្រធានគណបក្ស នរោត្តម រណប្ញទ្ធិ ឱ្យជាប់ពន្ធនាគារ១៨ឆ្នាំជាដើម។

ការអង្កេតនេះរកឃើញថា សារព័តិមានកោះសន្តិភាព (ផ្សាយពីគណបក្សប្រជាជនកម្ពុជា៦អត្ថបទ និងគណបក្ស ផ្សេងទៀតរួមគ្នា៣អត្ថបទ) ហាក់មានតុល្យភាពសមធម៌ច្រើនជាងសារព័តិមានរស្មីកម្ពុជា (ផ្សាយពីគណបក្សប្រជាជន កម្ពុជា ១៣អត្ថបទ និងគណបក្សផ្សេងទៀតរួមគ្នាចំនួន៣អត្ថបទ)។

អត្ថបទដែលមានលក្ខណៈអប់រំអ្នកបោះឆ្នោតត្រូវបានផ្សព្វផ្សាយចំនួនតែ៤អត្ថបទប៉ុណ្ណោះដោយសារព័តិមានទាំង ពីររួមគ្នា។

អត្ថបទដែលមានការអំពាវនាវជាចំហរឱ្យបោះឆ្នោតជូនគណបក្សនយោបាយមានយ៉ាងតិចចំនួន៣ដែលផ្សាយដោ យសារព័តិមានកោះសន្តិភាពដូចជាការផ្សាយនៅថ្ងៃទី៧
ខែមីនាដែលមន្ត្រីគណបក្សប្រជាជនកម្ពុជាអំពាវនាវឱ្យសមាជិកគណបក្សប្រជាជនកម្ពុជាជ្រើសរើសគណបក្សនេះសំរាប់ដឹ កនាំប្រទេស និងមួយអត្ថបទផ្សាយដោយសារព័តិមានរស្មីកម្ពុជា។

**សូមអរគុណ!**

*បេសកកម្មទី ២ ក្នុងចំណោមបេសកកម្មទាំងពីរ របស់ ខុមហ្វ្រែល គឺ "ជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ដែលក្នុងនោះសាធារណជន យល់យ៉ាងច្បាស់អំពីដំណើរការលទ្ធិប្រជាធិបតេយ្យ មិនត្រឹមតែមុនពេលបោះឆ្នោតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្រោយ និងចន្លោះពេលបោះឆ្នោតទៀតផង។ ដើម្បីសំរេចបេសកកម្មនេះ ខុមហ្វ្រែល រៀបចំការអប់រំ និងវេទិកាសាធារណៈ ក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសម្រេចនានា។ លើកទឹកចិត្តការចូលរួមការតស៊ូមតិ បញ្ចុះបញ្ចូល ដើម្បីឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោត ដែលបង្កើននូវគណនេយ្យភាព(ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត។ និងចុងក្រោយ ដោយផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័សដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលម្អៀង និងមិនប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្ត ការងាររបស់មន្ត្រីជាប់ឆ្នោត។"*

*សំរាប់ព័ត៌មានលំអិតសូមទាក់ទង:*

- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ០១២ ៩៤២ ០១៧
- លោក **ម៉ារ សុផល** ប្រធានផ្នែកអង្កេត ខុមហ្វ្រែល ០១២ ៨៤៥ ០៩១
- លោក **កុយ ចំនួនដារិទ្ធ** ប្រធានផ្នែកព័ត៌មាន ខុមហ្វ្រែល ០១២ ៨៤៦ ២១១